# តារាងមាតិកា

ទំព័រ


**សេចក្ដីថ្លែងការណ៍របស់បេក្ខជន** ..... **10**

**ព័ត៌មានអ្នកបោះឆ្នោត**

កម្រងសិទ្ធិអ្នកបោះឆ្នោត ..... 2
អ្នករួមចំណែកកំពូលៗ ..... 3
ធនធានគេហទំព័ររបស់លេខាធិការរដ្ឋ ..... 3
តាមដានសន្លឹកឆ្នោតរបស់អ្នក ..... 3
សារពីរដ្ឋលេខាធិការ ..... 4
កុំបង្អង់យូរ បោះឆ្នោតថ្ងៃនេះ! ..... 5
ចំនួនថ្ងៃកាន់តែច្រើន វិធីកាន់តែច្រើនដើម្បីបោះឆ្នោតជាមួយ VCA ..... 5
ការពិតរហ័ស ..... 6
ការបោះឆ្នោតនៅរដ្ឋ California ..... 7
ព័ត៌មានអំពីសេចក្ដីថ្លែងការណ៍របស់បេក្ខជន ..... 8
អ្នកបោះឆ្នោតតាមរដ្ឋបាលរថយន្ត California ..... 57
ព័ត៌មានឯកជនភាពនៃការចុះឈ្មោះបោះឆ្នោត ..... 57
សេចក្ដីជូនដំណឹងអំពីការបោះឆ្នោត ..... 58
សេចក្ដីជូនដំណឹងអំពីអំពើពុករលួយនៃដំណើរការបោះឆ្នោត ..... 59
លក្ខខណ្ឌតម្រូវនៃអត្តសញ្ញាណអ្នកបោះឆ្នោត និងការចុះឈ្មោះនៅរដ្ឋ California ..... 60
ការបោះឆ្នោតតាមប្រៃសណីយ៍ដែលអាចចូលប្រើបានពីចម្ងាយ ..... 61
ជំនួយសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព ..... 62
កាលបរិច្ឆេទដែលត្រូវចងចាំ ..... 63


# អ្នកចូលរួមចំណែកកំពូលៗចំពោះ បេក្ខជនរដ្ឋ

នៅពេលដែលគណៈកម្មាធិការ(បុគ្គល ឬក្រុមមនុស្សដែលទទួល ឬចំណាយប្រាក់សម្រាប់គោលបំណងដែលជះឥទ្ធិពលដល់អ្នកបោះឆ្នោតឱ្យគាំទ្រ ឬប្រឆាំងនឹងបេក្ខជន) រៃអង្គាសប្រាក់យ៉ាងហោចណាស់ $1 លាន គណៈកម្មាធិការនោះត្រូវតែរាយការណ៍ពីអ្នករួមចំណែកកំពូលទាំង 10 របស់ខ្លួន ទៅគណៈគណៈកម្មការការអនុវត្តនយោបាយដោយយុត្តិធម៌រដ្ឋ California (FPPC)។ គណៈកម្មការត្រូវតែធ្វើបច្ចុប្បន្នភាពបញ្ជីនៅពេលមានការផ្លាស់ប្តូរណាមួយ។

បញ្ជីទាំងនេះអាចរកបាននៅលើគេហទំព័រ FPPC តាមរយៈ៖
*fppc.ca.gov/transparency/top-contributors.html*

ដើម្បីស្រាវជ្រាវអំពីការចូលរួមចំណែកក្នុងយុទ្ធនាការឃោសនាបោះឆ្នោតសម្រាប់បេក្ខជន ឬវិធានការបោះឆ្នោត សូមចូលទៅកាន់ គេហទំព័ររបស់រដ្ឋលេខាធិការតាមរយៈ *powersearch.sos.ca.gov*។

# ចូលមើលគេហទំព័ររបស់រដ្ឋលេខាធិការ ដើម្បី៖

- មើលមគ្គុទ្ទេសក៍អ្នកបោះឆ្នោតនេះជាភាសាផ្សេងទៀតនៅ *voterguide.sos.ca.gov*
- ដើម្បីស្នើសុំមគ្គុទ្ទេសក៍នេះជាសំឡេង និងអក្សរធំៗ ឬជាភាសាអង់គ្លេស ចិន ហិណ្ឌូ ជប៉ុន ខ្មែរ កូរ៉េ អេស្ប៉ាញ តាហ្គាឡុក ថៃ និងវៀតណាមដោយមិនគិតថ្លៃ សូមចូលទៅកាន់ *vote.ca.gov*
- ស្វែងរកប្រអប់ទម្លាក់សន្លឹកឆ្នោត កន្លែងបោះឆ្នោត ឬមជ្ឈមណ្ឌលបោះឆ្នោតដែលនៅជិតអ្នកបំផុតនៅ *caearlyvoting.sos.ca.gov*
- ស្វែងរកការិយាល័យបោះឆ្នោត ឬមជ្ឈមណ្ឌលបោះឆ្នោតរបស់អ្នកនៅថ្ងៃបោះឆ្នោតនៅ *sos.ca.gov/elections/polling-place* ឬ *voterstatus.sos.ca.gov*
- សូមពិនិត្យមើលស្ថានភាពចុះឈ្មោះ និងព័ត៌មានចុះឈ្មោះរបស់អ្នកនៅ *voterstatus.sos.ca.gov*
- ទស្សនាលទ្ធផលបោះឆ្នោតផ្ទាល់បន្ទាប់ពីការិយាល័យបោះឆ្នោតបិទនៅថ្ងៃបោះឆ្នោតនៅ *electionresults.sos.ca.gov*

# តាមដានសន្លឹកឆ្នោតរបស់អ្នក

អ្នកបោះឆ្នោតទាំងអស់អាចទទួលបានព័ត៌មានថ្មីៗសំខាន់ៗលើសន្លឹកឆ្នោតរបស់ពួកគេតាមរយៈឧបករណ៍តាមដានផ្លូវការរបស់រដ្ឋ California សន្លឹ "តើសន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា?" (Where's My Ballot?)។ ការចុះឈ្មោះចំណាយពេលតិចជាងបីនាទី!

អ្នកអាចជ្រើសរើសទទួលការជូនដំណឹងអំពីស្ថានភាពសន្លឹកឆ្នោតរបស់អ្នកតាមរយៈសារជាអក្សរ (SMS) អ៊ីមែល ឬការហៅជាសំឡេង រួមទាំងការជូនដំណឹង ប្រសិនបើមានបញ្ហាណាមួយជាមួយសន្លឹកឆ្នោតរបស់អ្នក និងការណែនាំអំពីរបៀបកែតម្រូវវា ដើម្បីធានាថា សន្លឹកឆ្នោតរបស់អ្នកត្រូវបានរាប់។

កុំឲ្យឱកាសតាមដានសន្លឹកឆ្នោតរបស់អ្នកគ្រប់ជំហាននេះកន្លងផុតទៅឲ្យសោះ! សូមចូលទៅកាន់ *wheresmyballot.sos.ca.gov* ដើម្បីស្វែងយល់បន្ថែម។